**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
spring.parks.ps@education.vic.gov.au springparksps.vic.edu.au





ជំរាបមាតាបិតា/អាណាព្យាបាល,
នេះជាព្រឹត្តិបត្រព័ត៌មានចុងក្រោយនៃឆ្នាំ២០២២។

**សូមមើលខាងក្រោមអំពីរចនាសម្ព័ន្ធនៃការតែងតាំងបុគ្គលិកសាលាសំរាប់ឆ្នាំ២០២៣:**

យើងខ្ញុំមានការកែប្រែចំពោះការតែងតាំងបុគ្គលិកសំរាប់ឆ្នាំក្រោយ។Mrs Zaher នឹងសំរាកដើម្បីសំរាលកូននៅត្រីមាសទី១ឆ្នាំ២០២៣, ម្ល៉ោះហើយយើងខ្ញុំត្រូវរកគ្រូជំនួសនៅពេលអវត្តមានរបស់អ្នកគ្រូ។ Mrs Morgan នឹងទទួលបន្ទុកខាងកម្មវិធីអន្តរាគមន៍គណិតសាស្រ្ត,ហៅកាត់ថា EMU (Extending Mathematical Understanding).Mrs Morgan ធ្លាប់បានទទួលបន្ទុកខាងផ្នែកនេះពីដើមមកហើយៗធ្វើបានយ៉ាងល្អ។យើងខ្ញុំនឹងមិនបន្តកម្មវិធីអន្តរាគមន៍ខាងសរសេរនិងនិយាយនោះទេ,តែភ្ជង់អារម្មណ៍ទៅលើការគាំទ្រឲ្យកុមារយល់អំពីគំនិតខាងគណិត។ Mr Hesling នឹងបង្រៀនខាងកីឡា/កាយវប្បកម្មនៅសាខាទាំងពីហើយ Mrs Farmer & Mrs Mc Claren និងចែកវេនគ្នាបង្រៀនថ្នាក់ទី៥/៦នៅសាខាវ៉ាល្លីជាមួយនឹង Mrs Kenny.

**កំណត់ប្រចាំថ្ងៃ:៥/១២/២០២៣**

០៥/១២: បាយល្ងាចនៃក្រុមប្រឹក្សាសាលា:ម៉ោង៦:០០ល្ងាច
០៦/១២: ការប្តូរថ្នាក់ពីថ្នាក់មូលដ្ឋានដល់ទី៥
០៧/១២: កីឡាអត្តពលកម្មនៃសាលាទាំងមូលនៅសាខាវ៉ាល្លី
០៩/១២: គោរពទង់ជាតិ:ម៉ោង៣:០០ល្ងាច
ថ្នាក់មូលដ្ឋាននៃសាខាវ៉ាល្លីនឹងដើរទៅសាខាខាងលិច
១២/១២: ថ្នាក់មូលដ្ឋាននៃសាខាខាងលិចនឹងដើរទៅសាខាវ៉ាល្លី
ក្រុមឡានពេទ្យមកធ្វើទស្សនកិច្ចនៅសាខាវ៉ាល្លី
១៣/១២: ថ្ងៃបម្លាស់សាលានៃកុមារថ្នាក់ទី៦ទៅមធ្យមសិក្សា
ថ្ងៃសំរាកនៃកុមារពីថ្នាក់មូលដ្ឋានដល់ទី៥
១៤/១២: ក្រុមឡានពេទ្យមកធ្វើទស្សនកិច្ចសាខាខាងលិច
១៥/១២: របាយការណ៍សិស្សផ្ញើទៅផ្ទះ
១៦/១២: ថ្នាក់ទី៦ទៅលេងនៅមជ្ឍមណ្ឌលកីឡាស្ព្រីងវ៉េល
១៩/១២: ថ្ងៃប្រគល់សញ្ញាបត្រសំរាប់ថ្នាក់ទី៦
២០/១២: គោរពទង់ជាតិសាលាទាំងមូល:សាខាវ៉ាល្លី: ម៉ោង១០
សាលាបញ្ចប់នៅម៉ោង១:៣០ល្ងាចដើម្បីវិស្សមកាល

<table>
<tr><th>សាខាខាងលិច (WEST CAMPUS )</th><th>សាខាវ៉ាល្លី ( Valley Campus)</th></tr>
<tr><td colspan="2">បុគ្គលិកជំនាញ (Specialists):<br>សិល្បៈរចនា (Visual Arts) Melanie Lyons ( ថៃចន្ទ,ថ្ងៃពុធ, ) & Olga Megele (ថ្ងៃពុធ, ថ្ងៃព្រហស្បត៍)<br>កីឡា (Physical Education) Mr Josh Hesling នៅសាខាទាំងពីរ<br>ភាសាបរទេស:ភាសាអេស្ប៉ាញ៉ុល (LOTE - Spanish): Solange Parisi (ថ្ងៃច័ន្ទ – ថ្ងៃព្រហស្បត៍ )<br>សុខមាលភាពកុមារ (Student Wellbeing) : Sarah Shahsavand (ថ្ងៃព្រហស្បត៍នៅ Valley) ,<br>Angela Rousseau (ថ្ងៃច័ន្ទ និង ព្រហស្បត៍)<br>អន្តរាគមន៍គណិតសាស្រ្ត (Maths Intervention): Erin Morgan</td></tr>
<tr><td>ថ្នាក់មូលដ្ឋាន: (Foundation(Mawson)<br>Brent Addcock, Di Massey<br>ថ្នាក់ទី១និង២ (Year 1 and 2 (Mawson)<br>Jolita Curcio, Sally Cooper, Debbie Hancock, Rossana Law .<br>ថ្នាក់ទី៣និង៤ (Florey)<br>Louise Rakic, Simon Stroud, Julie Wirrick, Raman Kaur<br>ថ្នាក់ទី៥និង៦ (Year 5 and 6 (Florey)<br>Amanda Wong, Cam Adcock, Jacqui Swallow</td><td>ថ្នាក់មូលដ្ឋាន (Foundation (Mawson)<br>Kim Ary<br>ថ្នាក់ទី១និង២ (Year 1 and 2 (Mawson)<br>Anna Otenstein, Darren Lightfoot, Deanna del Rosario, Connie Fernandez<br>ថ្នាក់ទី៣និង៤ (Year 3 and 4 (Florey)<br>Carla Heffernan, Leigh Muscat, Anne Shafer<br>ថ្នាក់ទី៥និង៦ Year 5 and 6 (Flynn)<br>Dana McClaren/Leigh Farmer, Jo Kenny, Robyn Lazaridis</td></tr>
</table>

កុមារនឹងបានជួបគ្រូនិងមិត្តថ្មីសំរាប់ឆ្នាំក្រោយនៅថ្ងៃស្អែកដោយនៅជាមួយគ្នាសំរាប់រយៈពេលពីរម៉ោង។ កុមារសាលាយើងតែងតែរួមរៀនជាក្រុមជាមួយនឹងកុមារថ្នាក់ដទៃ, ដូច្នេះគ្រូៗអាចបំបែកកម្មវិធីសិក្សាចេញឲ្យកុមារទាំងឡាយឲ្យមានប្រសិទ្ធិភាព។

## ដំណឹងល្អ(តែគួរឲ្យក្រៀមក្រំ)

Mrs Siimpson ដែលធ្វើការនៅការិយាល័យសាខាខាងលិច,បានសម្រេចចិត្តចូលនិវត្តក្រោយពីបានធ្វើការចំនួន ២១ឆ្នាំនៅសាលាយើង។ នេះគឺជាការចូលនិវត្តមុនពេលកំណត់ដើម្បីស្វែងរកចំណូលចិត្តដទៃទៀត។នឹងទៅលេងហ្គលហ្វ៍ (golf),ហើយបន្ទាប់មកនឹងទៅទេសចរណ៏នៅឆ្នាំក្រោយជាមួយនឹងមិត្តភក្តិរបសគាត់។នេះគឺជាការសម្រេចចិត្តមួយសំរាប់ Mrs Siimpson ព្រោះគាត់ស្រឡាញ់សាលាយើង,ជាពិសេសទំនាក់ទំនងនឹងសិស្សសាលានិងគ្រួសារជារៀងរាល់ថ្ងៃ។ខ្ញុំមិនដឹងថាធ្វើដូចម្តេចដើម្បីរកអ្នកដទៃជំនួស, ព្រោះ Mrs Siimpson ជាផ្នែកមួយដ៏សំខាន់នៃក្រុមការងារដ៏ប្រសិទ្ធិភាពនៃសាលាយើង។នៅឆ្នាំក្រោយ, Mrs Siimpson នឹងត្រឡប់មកសាលាយើងវិញ ចំនួនពីរអាទិត្យដើម្បីបញ្ចប់ដំណើរការផ្ទេរការងារដល់អ្នកមកថ្មី,តែថ្ងៃទី១០/២ប្រាកដជាថ្ងៃចុងក្រោយរបស់Mrs Simpson . យើងខ្ញុំនឹងចាត់ចែងពិធីជប់លៀងសំរាប់ការចូលនិវត្តរបស់Mrs Siimpson ,តែមិនទាន់ដឹងពិតប្រាកដថាថ្ងៃណាឡើយ។

## កាលបិច្ឆេទនៃត្រីមាសសិក្សាសំរាប់ឆ្នាំ២០២៣:

ត្រីមាសទី ១:   ៣០/១-៦/៤

ត្រីមាសទី ២:   ២៤/៤-២៣/៦

ត្រីមាសទី ៣   ១០/៧-១៥/៩

ត្រីមសទី ៤:   ០២/១០-២០/១២

## សេចក្តីរំឭក:

ត្រីមាសទី៤នឹងបញ្ចប់នៅថ្ងៃអង្គារទី២០/១២/២០២២ វេលាម៉ោង១:៣០រសៀល។ ពិធីគោរពទង់ជាតិនឹងប្រព្រឹត្តទ្បើងនៅសាខាវ៉ាល្លី វេលាម៉ោង១០:០០ព្រឹកសំរាប់កុមារមាននាមក្នុងបញ្ជីសិស្សនៃត្រីមាស '',ហើយសេចក្តីប្រកាសនាមនៃសិស្សជាអ្នកដឹកនាំក៏នឹងបានប្រព្រឹត្តទ្បើងក្នុងថ្ងៃនេះដែរ។ គ្រួសារដែលមានកូនទទួលរង្វាន់,ឬជាសិស្សដឹកនាំ,នឹងបានទទួសំបុត្រអញ្ជើញឲ្យមករួមក្នុងពេលគោរពទង់ជាតិនេះ។

ត្រីមាសទី១នៃឆ្នាំសិក្សា ២០២៣ នឹងចាប់ផ្តើមនៅម៉ោង ៨:៥០ព្រឹក,ថ្ងៃច័ន្ទ ទី៣០ ខែមករា ២០២៣។

កុមារថ្នាក់មូលដ្ឋាននឹងសំរាករាល់ថ្ងៃពុធក្នុងខែកុម្ភៈទាំងមូលដើម្បីឲ្យគ្រូធ្វើតេសត៏ជាដំបូងតាមតម្រូវការពីក្រសួងអប់រំ។ គ្រួសារនឹងទទួលសំបុត្របញ្ជាកពីថ្ងៃដែលកុមារត្រូវមកធ្វើតេសត៏ជាមួយនឹងគ្រូ។

## សូមលាកុមារថ្នាក់ទី៦:

ពិធីអបអរសាទរនឹងប្រព្រឹត្តទ្បើងនៅWaltzing Matilda Hotel ចាប់ផ្តើមនឹងបាយល្ងាចហើយកុមានឹងញាំបាយល្ងាចជាមួយនឹងបុគ្គលិកសាលាមុននឹងមាតាបិតាមករួមក្នុងរាត្រីប្រគល់សញ្ញាបត្រនៅម៉ោង ៧:០០យប់នៅមហាសាលស្ព្រីងវើល(Springvale Town Hall)។

ខ្ញុំសូមជូនពរដ៏ល្អប្រពៃបំផុតដល់កុមារថ្នាក់ទី៦ក្រោយពីបានបញ្ចប់បឋមសិក្សា។

ដំណើរបន្ទាប់ក្នុងជីវិតសិក្សារបស់កុមារជិតចាប់ផ្តើមហើយ!

សូមឲ្យវិស្សមកាលនេះប្រកបដោយក្តីសុខនិងរីករាយដល់អ្នករាល់គ្នា,ហើយសូមជួបគ្នានៅឆ្នាំ២០២៣។

Julie Fisher
នាយកសាលា

## ថ្នាក់ទី១និង២ ធ្វើដំណើរសិក្សានៅសាលាវូតលី:

នៅខែវិច្ឆិកា,ថ្នាក់ទី១និង២នៃសខាទាំងពីរបានទៅលេងនៅសាលាវូតលី។យើងខ្ញុំរីករាយដោយបានលេងហ្គេមនៅបន្ទប់រៀនកាយវប្បកម្មនិងបន្ទប់លេងល្ខោន។យើងខ្ញុំឃើញសត្វកង់ហ្គូរូនិងកូនកង់ហ្គូរូកំពុងដេកនៅក្រោមម្លប់។យើងខ្ញុំក៏បានដាំដើមឈើនៅមណ្ឌលរក្សាព្រៃឈើ។ថ្ងៃនេះធាតុអាកាសក្តៅណាស់, តែយើងខ្ញុំមានការសប្បាយដោយបានជួបទាក់ទងនឹងសិស្សថ្នាក់ទី៨និងគ្រូ។







# ទិវាសំអាតសាលា

កាលពីថ្ងៃពុធមុន,ក្រុមពណ៌បៃតងបានចាត់ចែងទិវាសំអាតសាលានៅសាខាខាងលិច។ មានកុមារចំនួន៣០បានចូលរួមដោយពាក់ស្រោមដៃហើយរើសសំរាមទាំងឡាយដែលមាននៅជុំវិញសាលា។

សិស្សចំនួន៥ដែលរើសបានច្រើនជាងគេបង្អស់បានទទួលរង្វាន់។កុមារទាំង៥ដែលទទួលជ័យជំនះគឺ

Darrean, Celeste, Japneet, Kenny & Jayton.




## តុលេងកីឡាពីងប៉ុង



សូមអរគុណ John & Mike ដែលបានតម្លើងតុសំរាប់ លេងកីឡា ពីងប៉ុង











## អ្នកលេងកីឡាបាល់បោះ:ជំនាញ-បណ្តើរបាល់ម្តងពីរ







# STARS OF THE WEEK

## WEST CAMPUS

| Grade | Week 8 | Week 9 |
|---|---|---|
| FA | Nirlayp | Ellena |
| 1/2 A | Kenny | Angie |
| 1/2 B | Olivia | Terrance |
| 3/4 A | Japneet | Chase |
| 3/4 B | | Duong |
| 5/6 A | Ay Dar par | |
| 5/6 B | Qaseh | Jayden |
| Art | | Aja(FA),John(1&2)Humariah(1&2B),Eric(3&4B), Darrean(5&6B) |
| PE | Ailin | Emily (3&4A),Chase 3&4B) |
| Spani- | | Gemma (5&6B) |

## VALLEY CAMPUS

| Grade | Week 8 | Week 9 |
|---|---|---|
| FA | Alicica | Lewis |
| 1/2 L | Kylie | Britney |
| 1/2 M | Chanlida | Ekin |
| 3/4 L | Adam | Adam |
| 3/4 M | Theo | Alex |
| 5/6 L | Muaz | |
| 5/6 M | Yi Lian | Justin |
| Art | Vanessa | Hazel |
| PE | | Noah |
| Span- | | Lewis |